# brBaØb®tx.M

My B.A. diploma

YOU Sophea

ជីវិតរបស់មនុស្សគឺជាវាលវដ្តសង្សារដ៏វែងហើយឆ្ងាយ ឆ្ងាយដាច់និស្ស័យដាច់អាល័យនៃចិត្តសោកស្រណោះ។ កើតចាស់ ឈឺ ស្លាប់ គឺជាមរតកប្រចាំជីវិតនៃមនុស្សម្នាក់ៗ ដែលនឹងត្រូវទទួលដោយសមធម៌ និងដោយលើកដៃបដិសេធពាក្យថាស្លាប់នេះមិនបាន។

មាគ៌ានៃជីវិតរបស់មនុស្ស គឺត្រាច់ចរទៅតាមចង្វាក់នៃសង្គម។ សង្គមអាចលាបពណ៌មនុស្សពីសអោយប្រែទៅជាខ្មៅបាន។ ជនដែលផុតរលត់ជីវិតសង្ខារពីលោកនេះមានន័យថា គេបានឆ្លងផុតពីកម្មវេរាលោកិយ នៅតែអ្នកមានជីវិតទេដែលត្រូវមានកម្មប្រចាំកាយ មានភ័ព្វវាសនា សំដែងឆាកល្ខោនលោកិយនេះបន្តទៅទៀត ដែលសង្គមជាអ្នករើសមនុស្សមកសំដែងតួ មានតួស្លូត តួកាច អ្នកតូច អ្នកធំ ខ្ញុំគេ។ល។ ទោះបីជាចិត្តរបស់ខ្ញុំខំធ្វើការព្យាយាមអប់រំដួងចិត្តខ្លួនឯងថា «មនុស្សកើតមកត្រូវតែស្លាប់ទៅវិញជាច្បាប់ធម្មជាតិ» យ៉ាងណាក្តី ក៏ទឹកភ្នែករបស់ខ្ញុំនៅតែស្រក់ហូរលើផែនដីនេះដដែល ក៏ព្រោះតែម្តាយរបស់ខ្ញុំបានរលត់សង្ខារទៅថ្មីៗនេះ។

ដំណក់ទឹកភ្នែកក្នុងនាមជាបុរសដើមទ្រូងប្រាំហត្ថនៃខ្ញុំកំពុងតែស្រក់មកមិនដាច់ ឆ្លើយប្រាប់ថា ជាសញ្ញានៃវិប្បដិសារីជេរស្តីដាក់ទណ្ឌកម្មចំពោះដួងចិត្តខ្លួនឯង គ្មានពេលរសាយចាកទុក្ខា។ ខណៈនេះខ្ញុំកំពុងតែអង្គុយនៅមាត់ជណ្តើរផ្ទះបែរមុខទៅរកមាត់បឹងដំណក់ទឹកភ្លៀងរលឹមស្រិចៗ ផ្ទៃមេឃក៏ខ្មៅជុំជិតហាក់ដូចជាចូលមកដុតកំលោចដួងចិត្តរបស់ខ្ញុំ អោយទទួលបាននូវភាពកំសត់សោកាទ្វេឡើងថែមទៀត។ ធម្មជាតិផងទាំងពួងដែលមានទាំងប៉ុន្មាននៅក្នុងទឹកដីនេះគឺនៅតែថែរក្សាបាននូវភាពស្រស់ត្រកាលរបស់ខ្លួនអោយខ្ញុំបានយល់ដដែលទេ! ប៉ុន្តែទីស្ថាននេះលែងមានវត្តមានរបស់ម្តាយខ្ញុំទៀតហើយ! ព្រះអគ្គីបានបំផ្លាញរូប

## yUsPa

លោកកើតនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៨០ នៅទីក្រុងភ្នំពេញ។ លោកបានទទួលបរិញ្ញាបត្រអក្សរសាស្ត្រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅឆ្នាំ២០០២ ហើយបានចូលសិក្សាផ្នែកគរុកោសល្យនៅមហាវិទ្យាល័យគរុកោសល្យ។ លោកបានសរសេរប្រលោមលោកខ្នាតវែងមួយចំនួន ក្នុងនោះមានរឿងមួយបានជាប់ពានរង្វាន់ព្រះនាងឥន្ទ្រទេវី ឆ្នាំ២០០២។ ក្រៅពីនេះ លោកបានសរសេរប្រលោមលោកខ្នាតខ្លី និងកំណាព្យដែលមានចុះផ្សាយក្នុងទស្សនាវដ្តីប្រជាប្រិយ។

រាងកាយរបស់ម្តាយខ្ញុំអោយបែកធ្លាយទៅជា ដី ទឹក ភ្លើង ខ្យល់ដែលជាសភាវដើមវិញ។ ខ្ញុំយំ! ខ្ញុំខ្លោចផ្សា! គ្មានពេលស្បើយទុក្ខ ចិត្តក៏រលឹកបានឡើងវិញ នូវរឿងរ៉ាវពីអតីតកាលដ៏កំសត់ខ្លោចផ្សាល្វីងជូរចត់ ដែលជីវិតគ្រួសាររបស់ខ្ញុំបានភពប្រសព្វកន្លងមក។

តើហេតុអ្វីបានជាម្តាយរបស់ខ្ញុំស្លាប់?

គឺខ្ញុំ! ខ្ញុំជាអ្នកដែលធ្វើអោយម្តាយខ្ញុំស្លាប់!...

ខ្ញុំគឺជាជនម្នាក់ ដែលមានឈាមជ័រជាត្រកូលអ្នកកសិករ ដែលរស់នៅក្នុងទឹកដីខេត្តបាត់ដំបង ស្រុកមោងឫស្សី។ ទាំងខាងឪពុករបស់ខ្ញុំក្តី ទាំងខាងម្តាយរបស់ខ្ញុំក្តី គឺសុទ្ធតែមានបុព្វបុរសជាអ្នកធ្វើស្រែ រហូតនិស្ស័យនេះបានតភ្ជាប់មកដល់បច្ចុប្បន្នកាល។ ពាក្យថា «អ្នកស្រែ»មួយម៉ាត់ អ្នកមួយចំនួនដែលរស់នៅឃ្លាតឆ្ងាយពីជីវភាពនេះ ហើយប្រសិនបើជាជនដែលខ្វះការអប់រំទៀតនោះ ពាក្យនេះគឺអន់ថោកជាទីបំផុត ទាំងចំណេះវិជ្ជា ទាំងរបៀបរបបរស់នៅ រហូតមានជនមួយចំនួនពេលណាគេខឹងគ្នាឬចំអន់គ្នា គេតែងហៅគ្នាថា «អាអ្នកស្រែ» «មីអ្នកស្រែ» «កុំធ្វើមើលតែអ្នកស្រែ»។ល។ តែអ្នកទាំងនេះពុំបានគិតដល់គុណបំណាច់របស់ជីវិតអ្នកស្រែទាំងនេះ ដែលជាអ្នកផលិតអង្ករសំរាប់ផ្គត់ផ្គង់ជីវិតរបស់ខ្លួនពួកគេឡើយ ដោយគេសំអាងថា គេមានប្រាក់។ ឪពុករបស់ខ្ញុំឈ្មោះសាន គឺជាយុទ្ធជនពិការមួយរូប ដោយសារសង្គ្រាមក្នុងទសវត្សរ៍ទីប៉ែតសិបនៅតំបន់បរប៉ៃលិន ក្នុងខណៈពេលប្រទេសជាតិឆ្លងផុតពីរបបបនប្រល័យពូជសាសន៍ថ្មីៗ ដែលពេលនោះ ប្រទេសជាតិពុំទាន់មានសន្តិភាពបរិបូរណ៍នៅឡើយទេ។ ជើងរបស់ឪពុកខ្ញុំត្រូវគ្រាប់មីនពិការទាំងសងខាងដែលត្រូវអង្គុយលើរទេះរុញ រហូតមកដល់សព្វថ្ងៃ។

សង្គ្រាមបង្ហូរឈាមគ្នាពុំគ្រាន់តែធ្វើអោយពុករបស់ខ្ញុំរស់ក្នុងនាមជាជនពិការប៉ុណ្ណោះទេ លទ្ធផលក្រោយសង្គ្រាមទៀតសោត បានក្លាយជាអ្នកកំណត់ជោគវាសនានៃម្តាយរបស់ខ្ញុំអោយធ្លាក់ខ្លួនក្លាយទៅជាស្ត្រីពិការជើងស្តាំម្ខាង ដោយសារត្រូវគ្រាប់មីន ក្នុងពេលដែលម្តាយខ្ញុំទៅរកអុសក្នុងព្រៃ ហើយម្តាយរបស់ខ្ញុំត្រូវប្រើជើងសិប្បនិមិត្តរហូតមក។ ខ្ញុំបានចាំច្បាស់ថា នៅពេលដែលខ្ញុំមានអាយុប្រាំពីរឆ្នាំ ម្តាយខ្ញុំ សំរាលកូនទីបីដែលជាកូនពៅ។ ថ្ងៃនោះ ផ្ទះរបស់ខ្ញុំគ្មានប្រាក់មួយកាក់មួយសេនឡើយ អង្ករក៏អស់ពីពាងទៀត។ ជាលើកទីមួយនៃជីវិតរបស់ឪពុកខ្ញុំហើយ ដែលគាត់បានកាត់ផ្តាច់អស់នូវសេចក្តីខ្មាសអៀនចំពោះខ្លួនឯង និងចំពោះអ្នកដទៃ គឺពុកខ្ញុំនិងខ្ញុំ នាំគ្នាមកអង្គុយបត់ជើងសុំទានតាមសំយ៉ាបផ្សារ។ ជនសប្បុរសមួយចំនួនគេបានដាក់ទានដោយសណ្តានចិត្តសទ្ធាជ្រះថ្លា តែមានអសប្បុរសជនមួយចំនួនមិនត្រឹមតែមិនដាក់ទានទេ ថែមទាំងប្រើអាកប្បកិរិយាសម្តែងអោយឃើញច្បាស់នូវការមើលងាយស្អប់ខ្ពើម ពេបជ្រាយគួរអោយឈឺចាប់ជាទីបំផុត។ សំដីរបស់អ្នកស្រី

ម្នាក់នៅតែដក់ជាប់ក្នុងចិត្តរបស់ខ្ញុំជានិច្ច ទោះបីជាពេលវេលាកន្លងផុតទៅយ៉ាងយូរក៏ដោយ។ «មុខមាត់ សាច់ឈាម នៅគ្រាន់បើដែរ មិនគួរមកសុំទានគេសោះ! នៅភូមិខ្ញុំគេក៏ពិការអញ្ចឹងដែរ តែគេឡើងត្នោតអោយចំណាប់»។

ខ្ញុំឃើញពុករបស់ខ្ញុំខំញញឹមដើម្បីបន្លប់ចិត្តខ្មាសអៀន និងឈឺចាប់ឥតអ្វីផ្ទឹមនេះយ៉ាងជូរចត់។ តើមាននរណាទៅដែលគេយល់ ពេលស្រុកសង្គ្រាមគេពិតជាត្រូវការណាស់ជនដែលមានទឹកចិត្តក្លាហាន ពេលសុខក្សាន្តត្រាណ គេបោះបង់អ្នកចោល។ ជើងទាំងគូដែលពុករបស់ខ្ញុំបានបាត់បង់ទៅនេះ ក៏ព្រោះតែបុព្វហេតុជាតិមាតុភូមិបានតំរូវអោយឪពុករបស់ខ្ញុំយកព្រៃធ្វើផ្ទះ វត់កាត់ព្យុះភ្លៀង ព្រៃភ្នំក្រំថ្ម ធ្វើពលិកម្ម បូជាសាច់ស្រស់ឈាមស្រស់ជូនផែនដីពិតឥតមានស្តាយសង្ខារ។ គ្រប់គ្នាបានជ្រកក្រោមម្លប់នៃសុខសន្តិភាពនេះក៏បានមកពីការរួមចំណែករបស់ឪពុកខ្ញុំដែរ។ ប៉ុន្តែគេបែរជាបំភ្លេចនូវគុណូបការនេះចោល គេនាំគ្នារីករាយនឹងសន្តិភាព គេសប្បាយ គេអោយតំលៃ គេបំពាក់គ្រឿងឥស្សរិយយសអោយតែគ្នីគ្នាគេ គេបំភ្លេចជនតូចតាចអោយវេទនាខ្លោចផ្សាក្នុងវាលវដ្តសង្សារនេះ។ ម្តាយរបស់ខ្ញុំបានឆ្លងកាត់នូវជីវភាពមួយដ៏លំបាកវេទនារកថ្លែងមិនត្រូវ។ មួយថ្ងៃៗគ្មានពេលបានទំនេរព្រោះតែលក្ខខណ្ឌនៃជីវិតដែលហៅថា «ក្រ» បានតំរូវអោយម្តាយខ្ញុំក្រោកឈរឡើងប្រកបទៅដោយទឹកចិត្តភក្តីតស៊ូចំពោះគ្រួសារក្នុងនាមជាស្ត្រីពិការជើងម្ខាង។ ម្តាយរបស់ខ្ញុំបានតស៊ូអោយខ្ញុំនិងប្អូនៗបានរៀនសូត្រគ្រប់គ្នា ព្រោះតែគាត់ចង់អោយកូនមានចំណេះវិជ្ជាស្អប់ភាពល្ងង់ខ្លៅដែលជាទីស្អប់ខ្ពើមរបស់មនុស្ស។ ម៉ែខ្ញុំធ្វើស្រែ ដាំបន្លែ ចិញ្ចឹមសត្វ ដឹកកង់លក់បន្លែតាមភូមិស៊ីឈ្នួលស្ទូង ច្រូត អោយគេជាដើម។ ពុករបស់ខ្ញុំជាជាងជួសជុលកង់នៅខាងមុខផ្ទះ។

អាស្រ័យដោយការតស៊ូរបស់ម្តាយខ្ញុំ អោយខ្ញុំបានរៀនសូត្រ ទីបំផុតខ្ញុំក៏បានប្រលងជាប់សញ្ញាប័ត្រទុតិយភូមិ។ គ្រួសាររបស់ខ្ញុំទាំងមូលសប្បាយរីករាយយ៉ាងខ្លាំងចំពោះជ័យជំនះក្នុងការសិក្សារបស់ខ្ញុំ។ ប៉ុន្មានខែក្រោយមក គ្រួសាររបស់ខ្ញុំទាំងមូល ជាពិសេសម្តាយរបស់ខ្ញុំបានធ្លាក់ចូលទៅក្នុងសភាពមួយយ៉ាងក្រៀមក្រំ នោះដោយសារតែខ្ញុំប្រលងចូលរៀនបន្តនៅមហាវិទ្យាល័យមិនជាប់។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក៏ម្តាយរបស់ខ្ញុំបានលើកទឹកចិត្តខ្ញុំ មិនអោយអស់សង្ឃឹមឡើយដោយសន្យាថានឹងឱ្យខ្ញុំបានចូលរៀននៅមហាវិទ្យាល័យឯកជន។ យប់នេះម្តាយរបស់ខ្ញុំបានពិគ្រោះគ្នាជាមួយឪពុករបស់ខ្ញុំ ទាក់ទងនឹងរឿងបន្តការសិក្សា។ ទីបំផុតពុកក៏បានសំរេចអោយខ្ញុំចូលរៀននៅមហាវិទ្យាល័យឯកជន។ ប៉ុន្តែគាត់ត្រូវតែបញ្ឈប់ការសិក្សារបស់សុភាពជាប្អូនស្រីរបស់ខ្ញុំ ដែលនាងទើបតែប្រលងជាប់ឌីប្លូម ហើយបានចូលរៀននៅវិទ្យាល័យថ្មីៗ ដោយតំរូវអោយសុភាពទៅភ្នំពេញរកការងារនៅតាមរោងចក្រធ្វើ ដើម្បីជួយរកប្រាក់មកផ្គត់ផ្គង់ការរៀនសូត្ររបស់ខ្ញុំ។ ខណៈ

នោះ ខ្ញុំឃើញប្អូនស្រីរបស់ខ្ញុំអង្គុយយំម្នាក់ឯង។ សុភាពជាសិស្សដែលរៀនពូកែជាងគេក្នុងថ្នាក់។ សុភាពមិនចង់ឈប់រៀនទេ ឯម្តាយរបស់ខ្ញុំក៏មិនចង់អោយនាងឈប់រៀនដែរ ប៉ុន្តែស្ថានភាពនិងជីវភាពគ្រួសារជាអ្នកកាត់សេចក្តីអោយប្អូនស្រីរបស់ខ្ញុំត្រូវបង្ខំចិត្តលើកដៃលាចាកដំបូលសាលាទាំងទឹកភ្នែកអាលោះអាល័យជាទីបំផុត ដែលមួយជីវិតនេះគ្មានឱកាសណាមួយអនុញ្ញាតអោយរូបនាងបានវិលត្រឡប់មកសិក្សានៅលើទឹកដីនេះជាថ្មីម្តងទៀតឡើយ។

ទីបំផុតខ្ញុំក៏បានចូលរៀននៅវិទ្យាស្ថានជាតិគ្រប់គ្រងផ្នែក «ព័ត៌មានវិទ្យា» ដែលត្រូវបង់ប្រាក់ក្នុងមួយឆ្នាំបួនរយហុកសិបដុល្លារ។ ពុទ្ធោ! ទីក្រុងភ្នំពេញពិតជាអស្ចារ្យណាស់សំរាប់រូបខ្ញុំ។ មិត្តភក្តិរួមថ្នាក់ទាំងអស់ ភាគច្រើនសុទ្ធតែរស់នៅក្នុងជីវភាពសំបូរសប្បាយ គេមានលុយចាយ មានម៉ូតូសេរីថ្មីៗ មានទូរស័ព្ទទំនើបកាន់គ្រប់ដៃ។ ពេលនេះខ្ញុំចេះចាប់ផ្តើមមានអារម្មណ៍ខ្មាសអៀនចំពោះមជ្ឈដ្ឋានជុំវិញខ្លួន ព្រោះមានតែខ្ញុំម្នាក់ទេដែលត្រូវជិះកង់មករៀនជារៀងរាល់ថ្ងៃ។ យុវវ័យគឺពិតជាភ្លើតភ្លើនតាមគ្នាយ៉ាងប្រាកដ ខ្ញុំពុំអាចទ្រាំបានតទៅទៀតចំពោះសភាពលក្ខណៈបែបនេះឡើយ។ ខ្ញុំបានត្រលប់ទៅស្រុកកំណើតរំអុកម្តាយខ្ញុំអោយគាត់រកប្រាក់ទិញម៉ូតូអោយខ្ញុំបានជិះនឹងគេ។ ដោយប្រកែកមិនបាន ម្តាយខ្ញុំក៏យល់ព្រម ដោយប្រាប់ថា គាត់នឹងលក់ដីស្រែនៅខាងចុងភូមិ។ បើទោះជាខ្ញុំមានម៉ូតូម៉ាកគុប៥០ជិះក៏ដោយ នេះពុំទាន់គ្រប់គ្រាន់សំរាប់ខ្ញុំនៅឡើយទេ។ ខ្ញុំនៅចង់បានទូរស័ព្ទដៃមួយទៀត។ ម្តងនេះ ខ្ញុំបានទៅសុំប្រាក់ប្អូនស្រីរបស់ខ្ញុំចំនួន៧០ដុល្លារដោយកុហកថាយកទៅជួសជុលម៉ូតូ និងទិញសៀវភៅ។ សុភាពបានខ្ចីប្រាក់មិត្តភក្តិរបស់នាង បូករួមនឹងប្រាក់របស់នាង ក៏បានគ្រប់ចំនួនដែលខ្ញុំត្រូវការ។ ខ្ញុំបានប្រាក់ពីប្អូនស្រីហើយ ខ្ញុំក៏ប្រញាប់ទៅរកទិញទូរស័ព្ទដៃមួយគ្រឿងម៉ាកល្អល្មមប្រើការបាន។ ប្រាក់ដែលឪពុកម្តាយខ្ញុំផ្ញើមក សំរាប់ចាយវាយប្រចាំខែ ខ្ញុំឆ្លៀតទិញខោអាវថ្មីៗ ស្បែកជើងល្អៗ។ លុះពេលដាច់លុយ ខ្ញុំរត់ទៅសុំលុយប្អូនស្រីរបស់ខ្ញុំ ដែលជួលផ្ទះគេនៅម្តុំបឹងក្រពើ។

ពេលនេះគឺខ្ញុំអាចចូលចំណោមគេចុះហើយ ខោអាវក៏ថ្មីម៉ូតូក៏មានជិះ ទូរស័ព្ទក៏មានប្រើ ជីវិតរបស់ខ្ញុំឥឡូវនេះគឺពោរពេញទៅដោយឥស្សរភាពយ៉ាងអស្ចារ្យ។ ខ្ញុំមានមិត្តភក្តិជិតស្និទ្ធបួននាក់ដែលសុទ្ធតែជាកូនអ្នកមាន ជារៀងរាល់ថ្ងៃសៅរ៍អាទិត្យ ពួកយើងតែងតែនាំគ្នាជិះម៉ូតូជ្រែពេញផ្លូវ ហើយចូលច្រៀងកំសាន្តនៅតាមផ្លូវព្រែកលៀបមិនដែលដាច់។ បទដែលជាទីពេញនិយមរបស់ពួកយើងគឺជាបទញ័រញាក់តាមលំនាំបទបរទេស ជាពិសេសគឺបទថៃ។ ពួកយើងបាននាំគ្នាខំបំភ្លេចឱ្យអស់នូវអ្វីដែលជាវប្បធម៌របស់ខ្មែរ ហើយបើកខួរក្បាលនិងដួងចិត្តទទួលយកវប្បធម៌របស់បរទេសយ៉ាងពេញលេញជាទីបំផុត។

ខ្ញុំពុំបានយកចិត្តទុកដាក់ក្នុងការសិក្សារៀនសូត្របន្តិចណាសោះឡើយ ប្រាក់ថ្លៃឈ្នួលសាលា ខ្ញុំដឹងតែដល់ថ្ងៃខែកំណត់ខ្ញុំទៅយកពីផ្ទះ ត្រង់ចំនុចថា ប្រាក់នេះឪពុកម្តាយរបស់ខ្ញុំបានមកដោយស្ថិតនៅក្នុងរូបភាពលំបាកវេទនាយ៉ាងណាខ្លះនោះ គឺខ្ញុំពុំសូវជាចាប់អារម្មណ៍ឡើយ។ ខ្ញុំដឹងតែថាត្រូវប្រើជីវិតក្នុងនាមជាយុវវ័យ អោយមានន័យស្រស់បំព្រង និងដើរអោយទាន់នៃយុគសម័យទំនើប។ ពេលវេលានៃរដូវកាលចេះតែផ្លាស់ប្តូរទៅមុខឥតឈប់ឈរ មិនជាយូរប៉ុន្មានខ្ញុំក៏បានក្លាយទៅជានិស្សិតឆ្នាំទីបួន ឃើញថាវ័យរបស់ខ្ញុំកាន់តែទៅមុខ ក៏ប៉ុន្តែអត្តចរិតជាយុវជនឈាមរាវ ភ្លើតភ្លើនគឺនៅតែរក្សាទុកដូចគ្រាដើម។ ថ្ងៃមួយ ក្រុមរបស់ខ្ញុំបានដើរលេងរហូតដល់ម៉ោង១១យប់ ទើបចែកផ្លូវគ្នារៀងៗខ្លួន។ ពេលដែលខ្ញុំបញ្ឆាម៉ូតូសំដៅមកផ្ទះជួលដែលខ្ញុំស្នាក់នៅសព្វថ្ងៃនៅស្ទឹងមានជ័យនោះ ស្រាប់តែខ្ញុំបានត្រូវក្រុមបងធំមួយក្រុមប្លន់យកម៉ូតូរបស់ខ្ញុំបានយ៉ាងស្រួល នៅត្រង់ចំណុចគល់ស្ពានស្ទឹងមានជ័យដោយអាមេធំយកកាំភ្លើងមកភ្ជង់ក្បាលខ្ញុំ អោយខ្ញុំចុះពីលើម៉ូតូ។ បន្ទាប់ពីមានរឿងនេះមក ខ្ញុំលំបាកចិត្តខ្លាំងណាស់ ខ្ញុំក៏ពុំហ៊ាននិយាយរឿងនេះប្រាប់នរណាដែរ។ ល្ងាចនោះ ខ្ញុំក៏បានមកឈររង់ចាំប្អូនស្រីរបស់ខ្ញុំនៅពីមុខរោងចក្រកាត់ដេរ «ខិននីតិច»។ នៅក្រោមដំណក់ភ្លៀងរលឹមស្រិចៗ ខ្ញុំឃើញប្អូនស្រីរបស់ខ្ញុំកំពុងដើរចេញពីរោងចក្រទាំងទឹកមុខស្លេកស្លាំងគួរឱ្យអាណិតអាសូរ។ នាងមួយថ្ងៃៗអង្គុយដេររហូត ចំណីអាហារទៀតសោតក៏ហូបពុំគ្រប់គ្រាន់មួយពេលអស់តែ៦០០រៀល គឺបាយ៣០០រៀល សំល៣០០រៀល ឬបើឃ្លានខ្លាំង ថែមបាយស២០០រៀលទៀត។ នាងសន្សំសំចៃ ត្បិតត្បៀតនឹងខ្លួនឯង ដើម្បីដំណើរការនៃការរៀនសូត្ររបស់ខ្ញុំបានទៅមុខ។ ខ្ញុំមករកប្អូនស្រីរបស់ខ្ញុំ ក្នុងគោលបំណងប្រាប់នាងអោយដឹងពីរឿងដែលខ្ញុំត្រូវចោរប្លន់ម៉ូតូ ប៉ុន្តែដោយមើលទៅសភាពនៃសុខភាពរបស់នាងមិនសូវល្អ ខ្ញុំក៏សំរេចចិត្តលាក់រឿងនេះបន្តទៅទៀតដោយកុហកនាងថា ម៉ូតូខ្ញុំគឺមិត្តភ័ក្តិខ្ញីជិះ។

ថ្ងៃអាទិត្យនោះខ្ញុំក៏បានត្រឡប់មកស្រុកកំណើត ពេលមកដល់ផ្ទះ ខ្ញុំឃើញពុករបស់ខ្ញុំកំពុងអង្គុយផ្ទាល់នឹងដី រំកិលត្រឡប់ចុះឡើង ដើម្បីប៉ះកង់ម៉ូតូអោយគេ។ ខ្ញុំឃើញបាតដៃទាំងទ្វេរបស់គាត់ឡើងក្រិនដូចគូទស្វា។ ពេលឃើញខ្ញុំ ពុកយកខ្នងដៃមកជូតញើសលើថ្ងាស រួចហើយក៏ញញឹមដាក់ខ្ញុំយ៉ាងស្រទន់ បញ្ជាក់ពីទឹកចិត្តសណ្តោសប្រណីរបស់ឪពុកចំពោះរូបកូន។ ដោយអស់កំលាំងខ្លាំងពេក ខ្ញុំក៏ចូលទៅក្នុងផ្ទះរកកន្លែងសំរាក ហើយលក់ក្តាមមួយរំពេច។

ព្រលឹមឡើងស្រាងៗ ខ្ញុំក៏ដើរមួយៗសំដៅទៅស្រែខាងក្រោយផ្ទះ នៅក្រោមដំណក់ទឹកភ្លៀងរលឹមស្រិចៗនាដើមរដូវវស្សា។ ម្តាយរបស់ខ្ញុំកំពុងតែភ្ជួរស្រែ គឺអូសជើងភ្ជួរស្រែ ស្រាប់តែម្តាយរបស់ខ្ញុំទន់ជង្គង់ដួលគ្រឹបចុះទៅ។ គោចេះតែធ្វើដំណើរទៅមុខ ម្តាយខ្ញុំនៅដេកត្រាំក្នុងទឹក

ស្រែ គាត់ខំប្រឹងព្យាយាមក្រោកឈរតាមគោដើម្បីភ្ជួរបន្ត បានតែបន្តិច គាត់ក៏ដួលជាលើកទីពីរ។ ម្ដាយខ្ញុំដេកកាន់ដងនង្គ័លជាប់មិនអោយរបេះពីដៃឡើយ។ គោអូសម្ដាយរបស់ខ្ញុំទៅហើយ អូសទៅហើយ! ខ្ញុំក៏ប្រញាប់ស្ទុះរត់ទៅត្រកងកាយរបស់ម្ដាយខ្ញុំ បីត្រឡប់មកផ្ទះ អ្នកជិតខាងផ្អើលឈ្ងរឆមកជួយចាប់ខ្យល់ កោសខ្យល់ឱ្យម្ដាយរបស់ខ្ញុំ។ ក្រោយមក ម្ដាយខ្ញុំក៏បានធូរស្បើយជាងមុនច្រើន។ ពេលដែលខ្ញុំត្រឡប់មកភ្នំពេញវិញ អារម្មណ៍របស់ខ្ញុំដក់ជាប់ជានិច្ចមិនអាចបំភ្លេចបាននូវទិដ្ឋភាពនៃការតស៊ូមួយគ្រួសារ ដើម្បីបុព្វហេតុនៃការរៀនសូត្ររបស់ខ្ញុំ។

ថ្ងៃមួយនោះ ស្រាប់តែចៃដន្យអ្វីខ្ញុំក៏បានជួបក្រុមបងធំដែលខ្ញុំចំណាំមុខបានយ៉ាងច្បាស់ថា គឺជាក្រុមប្លន់ម៉ូតូរបស់ខ្ញុំ ស្រាប់តែដូចជាមានអំណាចអ្វីមកសណ្ឋិតក្នុងខ្លួនរបស់ខ្ញុំយ៉ាងពិតប្រាកដ ដោយតំរូវអោយខ្ញុំស្ទុះវឹងទៅដាល់ ធាក់ ទាត់ ពួកវាប្រៀបដូចជាខ្លួនឯងហ្នឹងជាតួឯកចិនហុងកុងដ៏ពូកែមួយរូបយ៉ាងអញ្ចឹង។ ប៉ុន្តែមិនទាន់ទាំងបានប៉ុន្មានវិនាទីផង ខ្ញុំក៏ត្រូវពួកវាព្រួតគ្នាវាយសងខ្ញុំវិញយ៉ាងចាស់ដៃ ប៉ុន្តែសំណាងល្អដែលមានប៉ូលិសនៅក្បែរនោះ ចូលមកធ្វើអន្តរាគមន៍ទាន់ពេលវេលា ហើយពួកវាក៏គេចខ្លួនអស់ទៅដែរ។ ចំណែករូបខ្ញុំត្រូវដឹកយកមកមន្ទីរពេទ្យដើម្បីធ្វើការសង្គ្រោះ។ ដំណឹងនេះក៏បានដឹងដល់គ្រួសាររបស់ខ្ញុំទាំងមូល។ ម្ដាយរបស់ខ្ញុំគោះទ្រូងយំ ហើយស្ដីបន្ទោសអោយខ្ញុំយ៉ាងច្រើន។ ខ្ញុំគ្មានពាក្យពេចន៍អ្វីសំរាប់និយាយឡើយ ព្រោះខ្ញុំស្គាល់ច្បាស់ថាលទ្ធផលនេះគឺជាអំពើដែលរូបខ្ញុំជាអ្នកកសាងដោយខ្លួនឯង ហើយក៏បានស្ងប់ចិត្តខ្លះដែរ កាលដែលបានស្ដាប់លឺនូវពាក្យស្ដីបន្ទោសរបស់ឪពុកម្ដាយខ្ញុំ ទោះជាយ៉ាងណាក៏ពួកគាត់មិនអាចបោះបង់រូបខ្ញុំចោលដែរ។

ខ្ញុំបានតាំងចិត្តចាប់ផ្ដើមកសាងខ្លួនជាថ្មី។ ខ្ញុំខិតខំរៀនសូត្រ ដើម្បីត្រៀមប្រលងបញ្ចប់ការសិក្សាផង និងខិតខំស្វះស្វែងរកការងារធ្វើនៅតាមក្រុមហ៊ុនផង។ ខ្ញុំបានចូលមកធ្វើសំភាសន៍នៅក្នុងក្រុមហ៊ុនមួយ មិនទាន់ទាំងបានសំភាសន៍ផង ស្រាប់តែមានបុរសសាច់ឈាមជាអ្នកមានម្នាក់ នាំយុវជនម្នាក់ក្នុងវ័យប្រហែលខ្ញុំ ចូលមកក្នុងបន្ទប់សំភាសន៍នេះដែរ ហើយនិយាយជាមួយអ្នកទទួលសំភាសន៍ថា «សុំផ្ញើក្មួយម្នាក់ផងសំលាញ់!»។ ខ្ញុំក៏ត្រូវបោះជំហានចាកចេញពីទីនេះទាំងអារម្មណ៍ឈឺចាប់ចំពោះសង្គមមានខ្សែនេះជាទីបំផុត បើមិនមានខ្សែទេជីវិតក៏ពិបាកនឹងជួបជោគជ័យណាស់។ មួយខែក្រោយមក ប្អូនស្រីរបស់ខ្ញុំបានជិះម៉ូតូឌុបឪពុកម្ដាយរបស់ខ្ញុំមកដល់ផ្ទះដែលខ្ញុំជួលនៅ។ ម៉ូតូម៉ាកគុប៩០ គឺម៉ូតូដែលពុកម៉ែទិញអោយខ្ញុំ ខ្ញុំត្រេកអរឥតឧបមាឡើយ។ តើបានប្រាក់មកពីណាទិញម៉ូតូនេះ? សំនួរនេះគ្មាននរណាម្នាក់អាចឆ្លើយនឹងរូបខ្ញុំបានឡើយ។ យល់នូវទឹកមុខដ៏ក្រៀមក្រំរបស់ពុកម៉ែរបស់ខ្ញុំ គឺអាចវាស់ស្ទង់បានច្បាស់ថា ប្រាក់ទិញម៉ូតូនេះគឺច្បាស់ជាលក់ដីស្រែជាក់ជា

មិនខាន។ ខ្ញុំចាប់ផ្តើមកាន់តែយល់ជ្រួតជ្រាបបានច្បាស់ នៅចំកណ្តាលនៃស្នាមញញឹមទាំងស្រពោនរបស់ពុកម៉ែ និងប្អូនស្រីរបស់ខ្ញុំ។ គឺខ្ញុំយល់ថា ជីវិតនេះគឺពោរពេញទៅដោយបន្លាស្រួច ច្រូងច្រាងងាកទៅខាងឆ្វេង ងាកទៅខាងស្តាំ គេស្រេះសុទ្ធតែរបងបន្លាស្រួចៗ ហើយខ្ពស់ៗចូលទៅមិនបាន។ មិនថាចំពោះតែអ្នកដទៃ ឬក៏ជាមិត្តភក្តិទេ គេច្រើនតែនិយមរាប់អានយើងក្នុងគ្រាមានបាន ឬក៏ក្នុងគ្រាសប្បាយហ៊ឺហាតែប៉ុណ្ណោះ។ គ្មាននរណាម្នាក់ស្រលាញ់រូបយើងស្មោះអស់ពីចិត្តពីថ្លើមដូចឪពុកម្តាយបង្កើតខ្លួនឯងឡើយ។ សេចក្តីស្រលាញ់របស់ឪពុកម្តាយជាសេចក្តីស្រលាញ់ដែលគ្មានលាក់គំនូចឬគ្មានល្បិចកល ដែលពួកគាត់បានប្រគល់មកឱ្យយើងដោយសុទ្ធចិត្ត និងមិនគិតពីផលតបស្នង។ បើទោះជាគាត់បន្ទោសឬខឹងយ៉ាងណា ក៏គាត់នៅតែចិត្តពុំដាច់ គឺជេរទៅនៅហៅមកវិញទេ តែបើអ្នកដទៃ បើគេជេរយើងហើយ គឺគេគុំស្អប់រូបយើងមួយជីវិតទល់នឹងថ្ងៃស្លាប់។ ខ្ញុំក៏បានខិតខំប្រឹងប្រែងតស៊ូព្យាយាមរៀនសូត្ររហូតប្រលងបញ្ចប់ការសិក្សា ដោយទទួលបាននូវលទ្ធផលគួរជាទីគាប់ចិត្តក្រៃលែង។ ប៉ុន្តែជាអកុសលអ្វី ស្រាប់តែខ្ញុំបានទទួលដំណឹងមកថា ម្តាយរបស់ខ្ញុំធ្លាក់ពីលើដើមស្វាយមានរបួសគ្រាំក្នុងជាទំងន់ ខ្ញុំក៏ប្រញាប់បញ្ឈាម៉ូតូឌុបប្អូនស្រីរបស់ខ្ញុំក្នុងល្បឿនយ៉ាងលឿន សំដៅមកស្រុកកំណើត។

ពេលមកដល់ផ្ទះ ខ្ញុំធ្លាក់ថ្លើមក្តុក ព្រោះឃើញម្តាយរបស់ខ្ញុំស្លៀកសំពត់ហូល និងអាវប៉ាក់ដែលគាត់ស្រលាញ់បំផុត ដែលពេលនេះគាត់កំពុងសណ្តូកកាយដ៏ស្គមស្គាំងរបស់គាត់នៅលើគ្រែឬស្សី ដែលនៅពីលើក្បាលដំណេកមានតាំងរូបព្រះពុទ្ធចូលនិព្វាន ហើយក៏មានស្លាធមិ បាយសីទៀន ធូប រៀបចំតាមរណ្តាប់យ៉ាងគត់មត់។ ម្តាយខ្ញុំផ្គុំដៃសំពះដាក់នៅត្រង់ប្រអប់ទ្រូង ហើយទន្ទេញពាក្យថា «ពុទ្ធោៗ» និងពាក្យធម៌មួយចំនួនទៀត ទៅតាមពាក្យបង្គាប់នៃលោកតាអាចារ្យ។ ពុករបស់ខ្ញុំមានប្រសាសន៍ទាំងទឹកភ្នែករលីងរលោង ÷

-ម្តាយឯងគ្រាំក្នុងយូរហើយ ព្រោះតែធ្វើការធ្ងន់ហួសកំលាំង គ្មានពេលសំរាកមិនថាជាការងារប្រុស ឬការងារស្រីទេ គឺម្តាយឯងរ៉ាប់រងទាំងអស់! មួយថ្ងៃៗអោយតត្រុក។ ប៉ុន្មានខែនេះ ម៉ែឯងខំប្រឹងខុសពីធម្មតា ដើម្បីរកប្រាក់ឱ្យបានច្រើនលោះយកដីស្រែមកវិញ។ ម៉ែឯងឡើងដើមស្វាយដើម្បីបេះផ្លែវាយកទៅលក់ តែអកុសលម៉ែឯងក៏ធ្លាក់ពីលើដើមស្វាយខាងក្រោយផ្ទះ ពេលនេះម៉ែឯងគ្មានសង្ឃឹមនិងរស់ទេ។

ខ្ញុំនិងសុភាពរួមទាំងប្អូនប្រុសពៅរបស់ខ្ញុំ នាំគ្នាស្រែកយំហ៊ូៗរហូតសំលេងនេះលឺដល់ម្តាយរបស់ខ្ញុំ។ ដោយកំស្អួលចិត្តនៃការរលឹកកូនខ្លាំងពេក ម្តាយខ្ញុំខំក្រោកអង្គុយទាំងត្រដាបត្រដួស។ ខ្ញុំនិងប្អូនស្រីរបស់ខ្ញុំស្ទុះចូលទៅជួយទប់អ្នកម្តាយ ដោយប្រយ័ត្នប្រយែង។ ម៉ែអង្អែលក្បាលពួកខ្ញុំយ៉ាង

ថ្នាក់ថ្នម រួចពោលទាំងទឹកភ្នែកហូររហាមនិងរលកសំលេងអួលអាក់÷
-ពីថ្ងៃនេះតទៅ ម៉ែអស់បាននៅឃើញមុខកូនៗទៀតហើយ! ពេលអត់ពីម៉ែទៅ ចូរកូនត្រូវចេះស្រលាញ់គ្នា ជួយគ្នា! កុំឈ្លោះគ្នាអោយសោះណាកូន។ ម៉ែគ្មានអ្វីជាកេរសំរាប់ពួកកូនទេ គឺម៉ែមានត្រឹមតែការតស៊ូ ក្រាញនៀលក្នុងឆាកជីវិតបង្ហូរញើសឈាមដើម្បីកូនៗ ដែលម៉ែធ្លាប់អួសលោងកន្លងមក ដែលមកដល់ពេលឥឡូវនេះ ម៉ែទៅលែងរួចហើយកូន អស់ត្រឹមថ្ងៃនេះហើយ!
-សំណាងកូន!
-បាទម៉ែ (ខ្ញុំឆ្លើយទាំងក្តាប់ដៃម្តាយជាប់)
-កូនជាកូនច្បង! កូនត្រូវមើលថែរក្សាប្អូនអោយបានល្អ! បំរើតបស្នងសងគុណអោយបានល្អផងចំពោះឪពុករបស់កូន ម៉ែស្លាប់ទៅបានបិទភ្នែកជិតហើយ! តែម៉ែនៅស្តាយ ស្តាយដែលម៉ែពុំបាននៅឃើញថ្ងៃដែលកូនឡើងទទួលសញ្ញាប័ត្រ។

លោកតាអាចារ្យបានតំរូវអោយបងប្អូនរបស់ខ្ញុំ នាំគ្នាចាកចេញពីទីនេះ ដើម្បីទុកឱកាសអោយម្តាយរបស់ខ្ញុំបានតាំងតំកល់សតិនៅក្នុងផ្លូវធម៌ ឈប់មានអារម្មណ៍វិលវល់ជាប់ជំពាក់ជាមួយកូនចៅទៀត។ ម្តាយខ្ញុំធ្វើគ្រប់យ៉ាងតាមឱវាទលោកតាអាចារ្យ គាត់លើកដៃផ្គុំសំពះក្នុងកិរិយារលឹកដល់គុណនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយពោលមិនដាច់នូវពាក្យថា «ពុទ្ធោ» មិនបានប៉ុន្មានផងម្តាយរបស់ខ្ញុំក៏អស់ខ្យល់ ហើយផុតរលត់សង្ខារពីលោកនេះ ដោយបន្សល់ទុកនូវសំណោកសោកសង្រេងយ៉ាងពន់ប្រមាណចំពោះរូបពួកខ្ញុំ ដែលជាកូន។ ពីថ្ងៃនេះទៅ ម៉ែសួនរបស់ខ្ញុំទៅរហូតហើយ។ សពរបស់ម្តាយខ្ញុំត្រូវបានរៀបចំធ្វើទៅតាមទំនៀមទំលាប់ប្រពៃណីពីបុរាណកាល ហើយរូបខ្ញុំគឺជាអ្នកបួសមុខភ្លើង។

ថ្ងៃទទួលបរិញ្ញាប័ត្រក៏បានមកដល់ ថ្ងៃនេះខ្ញុំបានពាក់អាវធំ ពាក់មួកធំយ៉ាងស្រស់សង្ហាឡើងទទួលបរិញ្ញាប័ត្រ។ មិត្តភក្តិទាំងអស់គេនាំគ្នាថតរូបជុំគ្នាជាមួយឪពុកម្តាយ បងប្អូន ក្រុមគ្រួសាររបស់គេរៀងខ្លួន។ ខ្ញុំដើរមកឈរនៅកន្លែងស្ងាត់តែម្នាក់ឯង។ ខ្ញុំលើកបរិញ្ញាប័ត្រមកពិនិត្យមើលទាំងស្រក់ទឹកភ្នែក ព្រោះតែនៅក្នុងបរិញ្ញាប័ត្រនេះ ខ្ញុំហាក់ដូចជាឃើញច្បាស់នូវរូបពុករបស់ខ្ញុំកំពុងអួសគូទប៉ះកង់អោយគេ បែកញើសជោគខោអាវមើលមិនយល់ បាតដៃក្រិនគួរអោយញញើត។ ខ្ញុំក៏ឃើញរូបប្អូនស្រីរបស់ខ្ញុំកំពុងអង្គុយដេរក្នុងរោងចក្រ ឃើញនាងអង្គុយញាំបាយនៅមុំមុខរោងចក្រ ដែលហ៊ុំព័ទ្ធទៅដោយធូលី និងផ្សែងយានយន្តគ្រប់ប្រភេទ។ រូបដែលខ្ញុំមើលឃើញច្បាស់ជាងគេនោះ គឺរូបម្តាយរបស់ខ្ញុំដែលដឹកបន្លែដើរលក់តាមភូមិ ស៊ីឈ្នួលដកស្ទូងច្រូតកាត់ បោកបែនអោយគេ ឃើញម្តាយរបស់ខ្ញុំអួសជើងភ្ជួរស្រែនៅក្រោមដំណក់ទឹកភ្លៀងនាដើមរដូវវស្សា។ ខ្ញុំបាន

ដឹងថាមិត្តភក្តិរបស់ខ្ញុំមួយចំនួន ដែលមានឪពុកម្តាយជាអ្នកជំនួញធំៗ គេជួញមួយថ្ងៃ គេមានប្រាក់ចាយបានមួយខែឬមួយឆ្នាំ។ ឯមិត្តភក្តិមួយចំនួនដែលមានឪពុកម្តាយជាមន្ត្រីធំៗនោះ គេស៊ីញ៉ែតែមួយខ្ទាក គេមានប្រាក់ចាយហូរហៀរ។ ឆ្លងកាត់នូវរឿងរ៉ាវមិនល្អរបស់ខ្ញុំកន្លងមក ខ្ញុំចោទសំនួរសួរខ្លួនឯងដោយចិត្តខ្មាសអៀនចំពោះខ្លួនឯងថា «តើខ្ញុំជានរណា? ឪពុកម្តាយរបស់ខ្ញុំមានឋានៈជាអ្វី?» បានជាខ្លួនខ្ញុំតាំងជីវិតអោយធ្លាក់ចូលទៅក្នុងសេចក្តីភ្លើតភ្លើនសម្បើមម្ល៉េះ? តើឪពុកម្តាយរបស់ខ្ញុំមានអ្វីយកទៅលក់? មានអ្វីយកទៅស៊ីញ៉ែ? គឺមានតែនង្គ័លយកទៅស៊ីញ៉ែនៅលើដីស្រែ តំនក់ញើសឈាម ទឹកភ្នែករបស់ម្តាយខ្ញុំដែលស្រក់នៅលើដីស្រែ គឺប្រៀបដូចជាតំនក់ទឹកខ្មៅ ដែលសំរាប់ផិតសំណៅអោយមើលឃើញកាន់តែច្បាស់នៃស្នាមរាស់។

ខ្ញុំដើរចេញមកខាងក្រៅបរិវេណ «វិទ្យាស្ថានជាតិគ្រប់គ្រង» ស្រាប់តែខ្ញុំភ្ញាក់ព្រើត គឺដោយសារខ្ញុំឃើញប្អូនស្រីរបស់ខ្ញុំកំពុងឈររុញរទេះឪពុករបស់ខ្ញុំ ហើយញញឹមយ៉ាងស្រស់មកកាន់រូបខ្ញុំ។ ខ្ញុំរត់ទៅឱបឪពុករបស់ខ្ញុំ។ ខ្ញុំលែងខ្មាសអៀនចំពោះនរណាដូចគ្រាមុនទៀតហើយ ទោះបីជាឪពុករបស់ខ្ញុំជាជនពិការក្តី ក៏ពិការព្រោះតែបុព្វហេតុជាតិ មាតុភូមិ ដែលខ្ញុំជាកូនត្រូវតែមានមោទនភាពទៅវិញទេ។ សុភាពញញឹមទាំងទឹកភ្នែករំភើប ពេលសំលឹងមួកធំ និងអាវធំរបស់ខ្ញុំ។ ខ្ញុំពិតជាយល់ណាស់ថា ប្អូនស្រីខ្ញុំកំពុងគិតអ្វីនោះ? គោលបំណងរបស់ប្អូនស្រី គឺចង់ក្លាយទៅជាគ្រូបង្រៀនដ៏ល្អម្នាក់ ប៉ុន្តែជាអកុសលលក្ខខណ្ឌនៃជីវិតបានកំរិតអោយរូបនាងមានឋានៈត្រឹមតែជាកម្មការិនី អង្គុយដេរប្តូរយកទឹកប្រាក់មកផ្គត់ផ្គង់ការរៀនសូត្ររបស់ខ្ញុំដែលជាកូនប្រុសទៅវិញ។ ខ្ញុំគិតថា នេះជារឿងមួយអយុត្តិធម៌សំរាប់ប្អូនស្រីរបស់ខ្ញុំណាស់ ដែលមានជីវិតកូនស្រីមិនតិចទេដែលមានលំនាំរឿងបែបនេះ។

និស្សិតទាំងអស់ដែលចេញមកខាងក្រៅ គឺគ្មាននរណាម្នាក់មើលរំលងនូវទិដ្ឋភាពដែលបីនាក់ឪពុកកូនយើងកំពុងយំដោយសេចក្តីរំភើបនេះឡើយ។ ខ្ញុំតាំងចិត្តសច្ចាថា សូមអោយក្រសែភ្នែកនៃគ្រប់បញ្ញាជនទាំងអស់ក្រឡេកមើលមកអោយបានគ្រប់ៗគ្នា។ សូមអោយអ្នកយកចំណេះដឹងទាំងប៉ុន្មានដែលបានក្រេបជញ្ជក់ពីទីនេះ យកទៅអនុវត្តនៅក្នុងសង្គម បំរើសង្គមប្រកបទៅដោយសីលធម៌ គុណធម៌ សច្ចធម៌ ជៀសវាងការយកចំណេះទៅប្រើក្នុងផ្លូវមិនល្អ គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន បក្សពួក ពុករលួយ ស៊ីសំណូកសូកប៉ាន់ ដែលទាំងនេះសុទ្ធតែជាផ្លូវនៃសេចក្តីវិនាសរបស់ប្រទេសជាតិ និងឈានទៅរកសង្គ្រាមបង្ហូរឈាមគ្នា ដែលពាក្យថា «សង្គ្រាម» និងលទ្ធផលនៃសង្គ្រាមមានសភាព និងរូបភាពវេទនាដល់កំរិតណានោះ គឺគ្រួសាររបស់ខ្ញុំទាំងមូលបានស្តែងអោយឃើញយ៉ាងប្រត្យក្សរួចជាស្រេចទៅហើយ។ ខ្ញុំក៏តាំងចិត្តអធិដ្ឋានសូមអោយក្រសែញញឹម

របស់បញ្ញាវ័ន្តគ្រប់រូបមានន័យបរិសុទ្ធនៃខ្សែជីវិតរបស់ខ្លួនបែបនេះរហូតតរៀងទៅ សូមអោយការកៀកស្មាគ្នាថតរូបទុកជាអនុស្សាវរីយ៍តំណាងអោយការរួបរួមសាមគ្គីគ្នា ក្នុងទិវានេះ នៅតែមានតំលៃស្អិតស្អេររឹងមាំ បរិសុទ្ធស្មោះត្រង់នឹងគ្នា មិនរស់នៅក្នុងសេចក្តីប្រមាថបៀតបៀនគ្នា ពោលគឺរស់នៅប្រកបទៅដោយសេចក្តីបរិសុទ្ធនៃជីវិតចិត្តថ្លើមមិនប្រែសាបសូន្យ វិស័យបីដូចជាទឹកចិត្តរបស់បុព្វបុរសខ្មែរ នាសម័យអង្គរដ៏រុងរឿងនៃយើង។

រឿងរ៉ាវពីអតីតកាលរបស់ខ្ញុំក៏ត្រូវបានបញ្ចប់ ខ្ញុំមានកំលាំងចិត្តរស់មកដល់សព្វថ្ងៃនេះ គឺដើម្បីបំពេញនូវបណ្តាំរបស់ម្តាយខ្ញុំ ដែលជាចំលើយដែលរូបខ្ញុំត្រូវឆ្លើយតបដោយខានមិនបាន និងជាផ្លូវមួយដើម្បីតបស្នងសងគុណ បំពេញនូវភាពជាកតញ្ញូកតវេទីចំពោះពលិកម្មរបស់ឪពុកខ្ញុំ ប្អូនស្រី ជាពិសេសគឺរូបអ្នកម្តាយរបស់ខ្ញុំផ្ទាល់តែម្តង។ ម្តាយខ្ញុំស្លាប់ ខ្ញុំបានកោរសក់បួសមុខភ្លើង។ ក្នុងថ្ងៃដែលខ្ញុំបានបំពេញនូវកាតព្វកិច្ចជាកូន ជាបង ជាពលរដ្ឋល្អល្មមដល់កាលវេលាមួយសមគួរហើយ ខ្ញុំតាំងចិត្តសច្ចាថា ខ្ញុំនឹងកោរសក់បួសជាថ្មីម្តងទៀត ប្រាថ្នាសូមរស់ជ្រកនៅក្រោមម្លប់ដ៏សែនត្រជាក់នៃព្រះពុទ្ធសាសនា ដរាបណាអស់ជីវិតសង្ខារនៅលើភពផែនដីដ៏គួរអោយសោកសង្វេគនេះ៕